3

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤

**លេខ:**......293........**អយក.**[illegible]

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**ជំរាបមក**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង**

**កម្មវត្ថុ** : ការរៀបចំធ្វើសំនួរសរសេរដើម្បីដាក់ពិន្ទុប្រចាំខែ

**យោង** : - លិខិតលេខ ២៧៥៥ អយក.ហវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការយកវិភាគទាន រឺការប្រមូលប្រាក់គ្រប់រូបភាព រឺការសុំសំភារៈផ្សេងៗពីសិស្ស មាតាបិតាសិស្ស សំរាប់ឆ្នាំសិក្សា ២០០២-២០០៣ នៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ។

- សេចក្តីណែនាំលេខ ៩៨៤ អយក.សណន ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីវិធានការទប់ស្កាត់បាតុភាពអវិជ្ជមាននានានៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ។

រយៈកាលកន្លងមកនៅតាមគ្រឹះស្ថានមធ្យមសិក្សាខ្លះ នៅតែកើតមានបាតុភាពឆ្លៀតយកលុយសិស្សតាមរូបភាពលក់មេរៀន រឺសំនួរត្រួតពិនិត្យប្រចាំខែនៅឡើយ ដែលជាប្រការផ្ទុយនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

ចំពោះករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំដូចខាងក្រោម ÷

១. ហាមដាច់ខាត មិនអោយថតចំលងមេរៀនលក់អោយសិស្ស ទោះជាមេរៀនសង្ខេបក្តី ព្រោះសិស្សមានសៀវភៅសិក្សាគោលហើយ ។

២. ចំពោះការធ្វើសំនួរត្រួតពិនិត្យ គប្បីអោយសិស្សធ្វើនៅលើក្រដាសសៀវភៅរបស់ខ្លួនដោយ ÷

-គ្រូចំលងសំនួរទាំងប៉ុន្មានលើក្តារខៀនដែលមានរាំងននបិទ អោយសិស្សឆ្លើយដោយគ្រាន់តែសរសេរលើក្រដាសសៀវភៅនូវចំនងជើងចំលើយណាដែលសិស្សយល់ថាត្រឹមត្រូវ ។ ក្នុងករណីនេះបន្ទប់រៀននីមួយៗត្រូវមានរាំងននបិទក្តារខៀន ដោយចំណាយថវិកា PAP ។

-គ្រូចំលងសំនួរទាំងប៉ុន្មានលើផ្ទាំងក្រដាសខ្នាតធំ (Poster) យកមកបិទនៅលើក្តារខៀន ហើយអោយសិស្សសរសេរចំនងជើងចំលើយណាដែលខ្លួនយល់ថាត្រឹមត្រូវលើសន្លឹកកិច្ចការរបស់ខ្លួន ។ ករណីនេះ គ្រឹះស្ថាន

មធ្យមសិក្សាត្រូវផ្តល់ផ្ទាំងក្រដាសសធំដល់គ្រូ ដោយប្រើថវិកា PAP ។

ចំពោះសំនួរទំរង់បើក គ្រូហៅសំនួរ រឺប្រធានបទអោយសិស្សចំលង និងឆ្លើយលើសន្លឹកកិច្ចការរបស់ខ្លួន ។

ក្រសួងសង្ឃឹមលើមនសិការ វិជ្ជាជីវៈ របស់លោក លោកស្រី ជាអ្នកគ្រប់គ្រង និងជាអ្នកបង្រៀនក្នុងការអនុវត្តតាមការណែនាំនេះ ដើម្បីរក្សាតំលៃជាអ្នកអប់រំផង និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សិស្ស មាតាបិតាសិស្សផង ។

សូមលោក លោកស្រី ប្រធានមន្ទីរយកចិត្តទុកដាក់តាមដានត្រួតពិនិត្យ និងកាត់បន្ថយ ឈានលប់បំបាត់បាតុភាពអវិជ្ជមាននេះអោយបានអស់ជាស្ថាពរ ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអ.យ.ក

  "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ នា.មចទ